**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ: ២៤៨
ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣
<u>សាលដីកា</u>
លេខ: ១៩៨
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ
<u>តុលាការកំពូល</u>

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................ ជាចៅក្រម
៦-លោក ................ ជាចៅក្រម
៧-លោក ............... ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ................ ជាចៅក្រមរបាយការណ៍

<u>ក្រឡាបញ្ជី</u>

-លោក ..................

<u>តំណាងមហាអយ្យការ</u>

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ពីសាលដីការដ្ឋប្បវេណីលេខ២២៤(ឈ)ចុះថ្ងៃទី១៩ខែធ្នូឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ មង(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរ ទីលំនៅផ្ទះលេខ ២៤៩ DEO+E1 ក្រុមទី២០ ផ្លូវទេពផន សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវីលោក ............

ចុងចម្លើយឈ្មោះ <u>បហ</u> (ជាម្ចាស់បណ្តឹងសាទុក្ខ) គេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១០១០ ផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌទួល គោក ក្រុងភ្នំពេញ ។

មានមេធាវី លោក ប៉ិច វិច្ឆិកា ជាតំណាង.

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារប្រាក់ .

បានឃើញបណ្តឹងសាទុក្ខលើកទី២លខ ៨៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះបហ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ ២២៤(ឈ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៣-៨-១៩៩៩ របស់ដើមចោទឈ្មោះម៉ង់ ងីម បញ្ជាក់ថា : ខ្លួនប្តឹងទារថ្លៃផ្ទះកើតហេតុពីចុងចម្លើយឈ្មោះបហ ចំនួន៥១.០០០ដុល្លាអាមេរិក និងជម្ងឺចិត្ត ចំនួន១០.០០០ដុល្លាអាមេរិក ដោយមូលហេតុថា ផ្ទះដែលខ្លួនកំពុងស្នាក់នៅសព្វថ្ងៃនេះ ខ្លួនបានទិញពីឈ្មោះបហ ក្នុងតម្លៃ៥១.០០០ដុល្លាអាមេរិក ដោយបានធ្វើកិច្ចសន្យាជានាខុសត្រូវគ្រប់ បែបយ៉ាងចំពោះបាតុភាពដែលបានកើតឡើង ។ ក្រោយពីខ្លួនចូលស្នាក់នៅមិនបានប៉ុន្មានខែផង ស្រាប់តែមានដំណឹងថា ឈ្មោះប៊ូន ហួ បានយកផ្ទះពាក់ព័ន្ធមកលក់ឱ្យខ្លួន ហើយថ្មីៗនេះ សាល ដីកាតុលាការកំពូល បានសម្រេចស្ថាពរ ប្រគល់ផ្ទះដែលខ្លួនបានទិញពី បហ ទៅឱ្យឈ្មោះលឹម សុខ ជាម្ចាស់កម្មសិទ្ធិវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣២(ក) ចុះថៃទី២២ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៣-៨-៩៧ របស់ដើមចោទឈ្មោះម៉ង់ ងីម ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យសុំពឹងពាក់មេធាវីចុះថ្ងៃទី០៤-០៩-៩៧ របស់រឈ្មោះបហ ឱ្យទៅមេធាវីចុង អៀវហេង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-បង្គាប់ឱ្យឈ្មោះបហ សងប្រាក់ចំនួន៥១.០០០ដុល្លាអាមេរិកជម្ងឺចិត្ត៥.០០០ដុល្លាអាមេរិក ឱ្យទៅឈ្មោះម៉ង់ ងីម វិញចាប់ពីថ្ងៃនេះតទៅ ។

៤-ករណីឈ្មោះប៊ូន ហួ រឹងទទឹងពុំព្រមសងប្រាក់ឱ្យទៅឈ្មោះម៉ង់ ងីមគ្រប់ចំនួនទេសម្រេចរឹបអូសទ្រព្យសម្បត្តិនិងដាក់គុកបង្ខំរូបកាយតាមមាត្រា១៣៣ នៃច្បាប់ស្តីពីការ អនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-បង្គាប់ឱ្យឈ្មោះបហ បង់ប្រាក់ប្រដាប់ក្តី៥០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៩០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួចស្រេច ។

កាលបើហួសកំណត់ឧទ្ធរណ៍ហើយ បង្គាប់ឱ្យឈ្មោះបហ សងប្រាក់៧០០០៛ ទៅឱ្យដើមចោទវិញ និងត្រូវបង់ពន្ធសមាមាត្រ១%លើប្រាក់ជំពាក់និងប្រាក់ជម្ងឺចិត្តប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន៨០%ព្រមទាំងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៦-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចំម្លើយ សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៧៨(ក)ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះប៊ុនហួ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៣២(ក)ទុះថ្ងៃទី២២-១០-៩៧របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចសាលក្រមទាំងមូល

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៤(ក) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះ បហ ចុះថ្ងៃទី០៦-១១-៩៧ ទុកជាត្រឹមត្រូវតាមច្បាប់ តែគប្បីបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៣២(ក) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ទុកជាបានការពេញទាំងមូល ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៧(ក) ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៩៨ របស់ឈ្មោះ ចុង អៀវហេង ជាមេធាវីតំណាងឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៤(ក) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេច ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦១៦ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ១៧(ក)ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨ របស់លោកចុង អៀវហេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៤(ក) ចុះថ្ងៃទី១៨-១៦-១៩៩៨ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ដោយឱ្យឈ្មោះបហ រួចផុតពីការប្តឹងទាមទារ ប្រាក់ថ្លៃលក់ផ្ទះនេះ ។

៣-រឹបអូសប្រាកប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធហ្នឹងនិងពន្ធចុះបញ្ជីក្តី២៥៥០៛ វង្វាន់ក្រឡាបញ្ជីភាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣០០៛ ។

កាលបើហួសបណ្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះម៉ង់ ងឹម សងប្រាក់ ១៣.០០០៛ នេះឱ្យទៅដើមបណ្តឹងឧទ្ធរណ៍វិញ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៥២ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះម៉ង់ ងឹម ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៦១៦ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤១ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៥២ចុងថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះម៉ង់ ងឹម ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦១៦ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣០៣ ចុះថ្ងៃទី១៤-១៦-១៩៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៥.០០០រ ដែលឈ្មោះម៉ង ងឹម បានបង់គឺ :

-ពន្ធចុះបញ្ជីក្តីនឹងពន្ធហ្នឹងចំនួន៤០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥០០រ សរុប១៩.០០០រ ហើយតម្រូវឱ្យលោកបហ សងប្រាក់ចំនួន១៩.០០០រ នេះទៅឱ្យលោកម៉ង់ ងឹម វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២៦(ឈ)ចុះថ្ងៃទី២៣ខែកក្កដាឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះរឿងរដ្ឋប្បវេណីលេខ៣៩ដុះថ្ងៃទី០៥-០៦-២០០៦ របស់សាលាឧទ្ធរណ៍សារជាថ្មីឡើងវិញតាមសាលដីការដ្ឋប្បវេណីលេខ៤១ ចុះថ្ងៃទី២៤-០៦-២០០២ របស់ តុលាការកំពូល ។

២-ទទួលស្គាល់ពាក្យសុំពឹងពាក់មេធាវីចុះថ្ងៃទី២២-០៤-២០០២ របស់លោក មេធាវីគី តិច ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ១៣២(ក) ចុះថ្ងៃទី២២-១០-១៩៩៧និងសាលក្រមរដ្ឋប្បវេណីចំពោះមុខលេខ១៤(ក)ចុះថ្ងៃទី១៨-១២-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹង២៥៥០រង្វាន់ក្រឡាបញ្ជីអាន់ហិបប្រាក់៤៥០រ ចំណាយលើការប្រគល់ដីកាកោះ៥០០០រ និងលើអាជ្ញាធរតុលាការ៥០០០រ សរុប១៣.០០០រ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខ ម៉ង់ ងឹម ចំពោះមុខមេធាវីការពារឱ្យដើមចោទកំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១៣៩ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះបហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១២២(ឈ) ចុះថ្ងៃទី២៣ខែកក្កដាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការប្បវេណីលេខ ២២៤(ឈ)ចុះថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៤-០៩-២០០៦ របស់ឈ្មោះបហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ១២២(ឈ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខលោកមេធាវីតំណាងឱ្យដើមចោទ(ម៉ង់ងីម ឡើង ,សុងឡេង) កំបាំងមុខដើមចោទ ម៉ង់ ងីម និងចុងចម្លើយបបហ សម្រេចបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៨៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះប៊ុន ហួរ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២២៤ (ឈ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៣១ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ។

២-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ខែធ្នូឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះជារឿងវិវាទប្តឹងទាមទារប្រាក់ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះម៉ង់ ងីម នាពេលសវនាការថា ខ្លួនសូមឱ្យតុលាការជួយដោះស្រាយរឿងនេះឱ្យខ្លួនផង ព្រោះថាផ្ទះនេះខ្លួនទិញពីបបហ ដូច្នេះខ្លួនត្រូវទារលុយពីបបហ វិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកប៉ិច វិច្ចិកា ជាមេធាវីការពារ និងជាតំណាងឱ្យចុងចម្លើយបានលើកឡើងថា : រឿងនេះមានកម្មវត្ថុតែមួយ ចុងចម្លើយតែមួយ ។ ខ្លួនសូមបន្ថែមនូវ ចំណុចខ្វះខាតមួយចំនួន រឿងនេះមានសាលក្រមចូលជាស្ថាពរហើយ ឈ្មោះម៉ង់ងីម ឡេងសុងហេង មិនបានប្តឹងទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ............ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : រឿងនេះមានកម្មវត្ថុតែមួយមានចុងចម្លើយតែមួយ ខ្លួនមិនបាច់និយាយវែងឆ្ងាយទៀតទេ ខ្លួនគ្រាន់តែបញ្ជាក់ថា កូនក្តីខ្លួនទិញផ្ទះពីបបហ កូនក្តីខ្លួនមានសិទ្ធិទារលុយពីបបហ វិញ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយរបស់លោកម៉ង់ ងីម និងសេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកបហ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនិងមាត្រា២២៦នៃនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីបានផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យឈ្មោះបហ សងប្រាក់ថ្លៃផ្ទះចំនួន៥១.០០០ដុល្លាអាមេរិកទៅលោកម៉ង់ ងឹម ទាំងស្រុងនោះជាការត្រឹមត្រូវទេ ដោយហេតុថា

+ លោក ម៉ង់ ងឹម ក្នុងឋានៈជាម្ចាស់កម្មសិទ្ធិនៃផ្ទះទំនាស់ និងជាម្ចាស់បណ្តឹង ឧទ្ធរណ៍បានចូលរួមជាភាគីនៃរឿងក្តីលេខ៣៨៩ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញរួចហើយៗមិនបានប្តឹងសាទុក្ខឡើយ ធ្វើឱ្យសាលក្រមក្នុងរឿងក្តីនោះបានចូលជាស្ថាពរ ដូចនេះចាត់ថា ភាគីលោកម៉ង់ ងឹម មានកំហុស ។

+ រីឯលោក បហ ក៏ត្រូវបានតុលាការក្រុងភ្នំពេញ បញ្ចូលជាតតិយជននៃរឿងក្តីលេខ៣៨៩ ចុះថ្ងៃទី២៣ខែកក្កដា ឆ្នាំ១៩៩៥ ដែរ ប៉ុន្តែមានការធ្វេសប្រហែសមិនបានប្រើសិទ្ធិរបស់ខ្លួន តាមផ្លូវច្បាប់ចូលរួមក្នុងនីតិវិធីរបស់តុលាការឡើយ ដោយមិនបានប្តឹងឧទ្ធរណ៍ ដែលអំពើនេះ ចាត់ថា លោកបហ ក៏មានកំហុសផងដែរ ។

- យល់ឃើញថា គូភាគីមានកំហុសដូចគ្នា ដូចនេះត្រូវមានកាតព្វកិច្ចសាមគ្គីភាពក្នុងការ ទទួលខុសត្រូវលើការខូចខាតដែលភាគីនីមួយៗត្រូវទទួលរង ។

- យល់ឃើញថា លោកបហ មិនបានចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវីរបស់លោកបានចូលរួម ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២២៤ (ឈ)ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ និងមេធាវីគូក្តី

## កំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកប៊ុនហួ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ឯគតិច្បាប់ត្រូវខ្លះ ខុសខ្លះ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២២៤(ឈ) ចុះថ្ងៃទី១៩ ខែធ្នូឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្គាប់ឱ្យលោកបហ សងប្រាក់ចំនួន២៥.៥០០$បទ(ពីរម៉ឺនប្រាំពាន់ប្រាំរយដុល្លាអាមេរិក) ឱ្យទៅលោកម៉ង់ ងឹម ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលដើមចោទបានបង់នៅតុលាការកំពូលគឺ

-ពន្ធចុះបញ្ជីក្ដីនឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

-បង្គាប់ឱ្យលោកបហ បង់ពន្ធសមាមាត្រចំនួន១%នៃប្រាក់ដែលត្រូវសង ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៣ខែកក្កដា ឆ្នាំ២០០៦ ។